# សេចក្តីថ្លែងការណ៍រួម
# ការបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាននៅកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣

ក្នុងទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពលើឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាន យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមដូចខាងក្រោម សូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាចាត់វិធានការជាក់លាក់ដើម្បីធានានូវការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងតម្លាភាព ទៅលើឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដែលបានប្រព្រឹត្តិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ចាប់តាំងពីឆ្នាំ១៩៩៤ យ៉ាងហោចណាស់អ្នកសារព័ត៌មានចំនួន១៥នាក់ត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមនោះ អ្នកសារព័ត៌មានចំនួន១២នាក់បានរាយការណ៍អំពីបញ្ហារសើបនៅពេលពួកគេត្រូវបានសម្លាប់។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានជនល្មើសណាម្នាក់ត្រូវបាននាំមកផ្តន្ទាទោសចំពោះករណីទាំងអស់នេះទេ។ និទណ្ឌភាពចំពោះបទឧក្រិដ្ឋក្រៅប្រព័ន្ធច្បាប់នៅកម្ពុជាមិនត្រឹមតែកំណត់ទៅលើការវាយប្រហារលើអ្នកសារព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែកង្វះខាតនូវការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងតម្លាភាព និងកង្វះនីតិវិធីព្រហ្មទណ្ឌត្រឹមត្រូវទៅលើសកម្មជនបរិស្ថាន លោក ឈុត វុទ្ធី សកម្មជនសហជីព លោក ជា វិជ្ជា និងលោក រស់ សុវណ្ណារ៉េត អ្នកវិភាគនយោបាយ លោកបណ្ឌិត កែម ឡី កាន់តែបង្ហាញពីការរីករាលដាលនៃវប្បធម៌និទណ្ឌភាពដែលមាននៅក្នុងប្រទេសកម្ពុជាបន្ថែមទៀត។ ករណីរៀបរាប់ខាងលើគ្រាន់តែជាផ្នែកមួយនៃករណីជាច្រើនទៀតនៃការរំលោភបំពានលើអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស សមាជិកនយោបាយជំទាស់ សហជីព និងសកម្មជនផ្សេងៗទៀតដែលករណីពួកគេមិនត្រូវបានដោះស្រាយពីសំណាក់ស្ថានប័នដែលមានតួនាទីការពារសិទ្ធិមូលដ្ឋាននៅក្នុងប្រទេសកម្ពុជានៅឡើយទេ។

ការយាយី និងឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មាននៅតែជាក្តីបារម្ភនៅឆ្នាំនេះ។ យោងតាមសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) អ្នកសារព័ត៌មានចំនួន៣០នាក់រងការយាយីក្នុងរយៈពេល១០ខែចុងក្រោយនេះ (ពីខែមករា ដល់ខែតុលា ឆ្នាំ២០២៣)។ ក្នុងចំណោមអ្នកសារព័ត៌មានទាំង៣០នាក់នេះ ២៣នាក់ទទួលរងអំពើហិង្សា និងការគំរាមកំហែង ៤នាក់ប្រឈមនឹងការយាយីតាមផ្លូវតុលាការ ២នាក់ត្រូវបានឃាត់ខ្លួនដើម្បីសួរចម្លើយ និងអាជ្ញាបណ្ណសារព័ត៌មានចំនួន៥ត្រូវបានដកហូត។

ការយាយី និងការធ្វើទុក្ខបុកម្នេញលើអ្នកសារព័ត៌មានដែលកំពុងរាយការណ៍លើប្រធានបទដែលជាប្រយោជន៍សាធារណៈ ធ្វើឱ្យប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិនិងសារព័ត៌មាន គំរាមកំហែងដល់ការទទួលបានព័ត៌មានរបស់សាធារណជន និងមានការពិបាកសម្រាប់ឱ្យបុគ្គលមានអំណាចទទួលខុសត្រូវនូវអ្វីដែលខ្លួនបានប្រព្រឹត្ត។ បន្ថែមពីនេះ នៅពេលដែលអាជ្ញាធរមិនបានធ្វើការស៊ើបអង្កេតត្រឹមត្រូវ និងផ្តន្ទាទោសឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន ជាសារមួយបង្ហាញថាឧក្រិដ្ឋកម្មបែបនេះត្រូវបានអនុញ្ញាត។

យើងខ្ញុំសូមថ្កោលទោសចំពោះអំពើនិទណ្ឌភាពដែលធ្វើឱ្យប៉ះពាល់ដល់ប្រជាជន និងសង្គមកម្ពុជា និងទាមទារយុត្តិធម៌សម្រាប់អ្នកទាំងឡាយណាដែលសិទ្ធិរបស់គេមិនត្រូវបានអើពើ។ យើងខ្ញុំសូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ផ្តន្ទាទោសដល់ជនល្មើសនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្សតាមរយៈការស៊ើបអង្កេតដោយឯករាជ្យ តម្លាភាព និងឆាប់រហ័ស ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលរួមបញ្ចូលទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ផែនការសកម្មភាពនៃអង្គការសហប្រជាជាតិស្តីពីសុវត្ថិភាពរបស់អ្នកសារព័ត៌មាន និងបញ្ហានិទណ្ឌភាព និងគោលការណ៍សម្រាប់ការពារ និងលើកកម្ពស់សិទ្ធិមនុស្សតាមរយៈសកម្មភាពប្រឆាំងនិទណ្ឌភាព ដែលបានធ្វើបច្ចុប្បន្នភាពដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ។

ជាយូរមកហើយ រដ្ឋាភិបាលបានខកខានក្នុងការនាំយកជនល្មើសដែលប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងអ្នកសារព័ត៌មានមកផ្តន្ទាទោស។ និទណ្ឌភាពត្រូវតែបញ្ចប់។

**សេចក្តីថ្លែងការណ៍នេះចូលរួមគាំទ្រដោយ៖**

សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (CamboJA)
មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)